ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីជាសះស្បើយ ០១នាក់ និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី
# នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **ចំនួនអ្នកព្យាបាលជាសះស្បើយ**សរុបទូទាំងប្រទេស មានចំនួន **១២៧នាក់** (ស្មើនឹង ៩៨,៤៥% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងបុរស ៨៨នាក់
- **អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត** មានចំនួន ០២នាក់ (ជាបុរស)៖
  - បុរសជនជាតិខ្មែរ ០១ នាក់ ដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ី
  - បុរសជនជាតិខ្មែរ ០១នាក់ ដែលជាករណីវិលត្រឡប់មកពីប្រទេសម៉ាឡេស៊ី
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់**នៅទូទាំងប្រទេស សរុបចំនួន **១២៩នាក់** (ស្រី ៣៩នាក់ និងបុរស ៩០នាក់)។

## ២. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

## ៣. ករណីព្យាបាលបានជាសះស្បើយ ចំនួន ០១នាក់

បុរសជនជាតិខ្មែរអាយុ ២២ឆ្នាំ មានអាស័យដ្ឋាននៅខេត្តកំពង់ចាម ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ហើយត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

## ៤. ការអំពាវនាវក្រើនរំលឹករបស់ក្រសួងសុខាភិបាល

យោងតាមស្ថានភាពបច្ចុប្បន្ននៃការរាតត្បាតនៃវីរុសកូវីដ-១៩នៅលើសាកលលោកមានសភាពខ្លាំងក្លានៅឡើយ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល** សូមធ្វើការអំពាវនាវក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ មិនត្រូវភ្លេចកិច្ចការពារខ្លួនពីការចម្លងជំងឺកាចសាហាវនេះ ដោយចេះកែប្រែទម្លាប់រស់នៅរបស់ខ្លួនឲ្យស្ថិតនៅក្នុងភាពប្រុងប្រយ័ត្នជាប់ជានិច្ច ដែលបុគ្គលគ្រប់រូបត្រូវរៀនសម្របខ្លួនតាមបែបដែលហៅថា "***ការរស់នៅធម្មតាតាមបែបគន្លងថ្មី***" ដោយប្រកាន់យកការបន្តអនុវត្តន៍វិធានការការពារការចម្លងវីរុសកូវីដ-១៩នេះឲ្យបានខ្ជាប់ខ្ជួន ជាមួយនឹងការ



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/ ៨៨៤ ៩០៩

ប្រុងប្រយ័ត្នទូវលកទី២នៃការចម្លងវីរុសដ៏កាចសាហាវនេះ ដែលអាចកើតមានគ្រប់ពេលវេលា គ្រប់កាលទេសៈ និងគ្រប់ទីកន្លែង មានដូចជា៖

- ត្រូវរក្សាអនាម័យដៃស្អាតដោយឧស្សាហ៍លាងដៃជាមួយទឹកស្អាតនឹងសាប៊ូ ឬទឹកអាល់កុល ឬទឹកដែលលាងដៃ ឲ្យបានញឹកញាប់
- ត្រូវពាក់ម៉ាស់ (ក្នុងករណីចាំបាច់ ជាពិសេសពេលធ្វើដំណើរដែលមានគ្នាច្រើន ឬនៅទីកន្លែងដែលមានមនុស្សម្នាច្រើន ជាដើម) ឬប្រើក្រមា កន្សែង ឬក្រដាសជូតមាត់ ខ្ទប់មាត់និងច្រមុះ នៅពេលក្អកកណ្តាស់
- ត្រូវអនុវត្តន៍គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ឲ្យបានលើសពីមួយម៉ែត្រកន្លះឡើង ជាដើម។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា